ចិន ជា មិត្ត របស់ នរណា ?

ពិនិត្យអំពីព្រឹត្តិការណ៍សំខាន់ៗមាននៅស្រុកខ្មែរ

សរសេរ ដោយ ឧប សៅ សង្ហា

មាតិការឿង

ចិន ជា មិត្ត របស់ យួន ? 2
ចិន ជា មិត្ត របស់ ខ្មែរ ? 10
សេចក្តីសន្និដ្ឋាន 14
សហការ ចិន និង យួន នៅ កម្ពុជាក្រោម 17
ឧបសម្ព័ន្ធ 19

ចិន ជា ទ្រព្យ របស់ យួន ?

ប្រវត្តិសាស្ត្រ នៃ ប្រទេស យៀកណាម ឈ្មោះ នៅ សម័យដើម ថា ដែ រ៉ៀត ជា ស្រុកមួយ ស្ថិត នៅក្នុង ដែនដី ដែល ប្រទេស ចិន ទុក ជា ដែនដី នៅក្រោម ការគ្រួតគ្រា របស់ខ្លួន តែ ស្រុក ដែ រ៉ៀត នេះ តែងតែ ទាមទារ អធិបតេយ្យភាព របស់ខ្លួន នៅ ចំពោះមុខ អនុត្តរភាព របស់ប្រទេសចិន។ កិរិយា នេះ នៅ សម័យនោះ វា ចោទ ជា បញ្ហា មួយសំខាន់ ដល់ នយោបាយ កិច្ចការ ក្រៅ ប្រទេស ចិន។ ប៉ុន្តែ មកដល់ សតវត្ស ទី១១ ក្នុង សន្ទតិវង្ស លី (LÝ) នៃ ប្រទេស យៀកណាម ព្រះចៅយួន មួយ អង្គ សំដែង ព្រះរាជហឫទ័យ ជា ផ្លូវការ ទុក ព្រះអង្គ ជា រាជ ធិរាជ នៃ នគរ ដែ រ៉ៀត ស្មើនឹង ព្រះរាជាធិរាជចិន នៃ សន្ទតិ វង្ស សុង។ នៅ ឆ្នាំ ១១៦៤ ក្នុង នយោបាយ រក ការរសាយ ទំនាស់ ជាមួយ ស្រុកយួន ព្រះចៅចិន តែងតាំង ជា ផ្លូវការ ព្រះ ចៅយួន ជា ព្រះមហាក្សត្រ នៃ ប្រទេស ចំណុះមួយ នៅក្រៅ ប្រទេស ចិន (Quoc vúòg)។ ការតែងតាំង នេះ ជា ការទទួល ស្គាល់ ជា ផ្លូវការ ថា ស្រុកយួន ជា ប្រទេសមួយ នៅក្រៅ ប្រព័ន្ធ រដ្ឋបាល នៃ អាណាចក្រ ចិន។ លក្ខន្តិក: ជា ផ្លូវការ នេះ បាន ត្រូវ ទុក ជា ទំនាក់ទំនង នាយក ចិន និង យួន ដែល ព្រះចៅ យួន និង ចិន បន្តៗមក ប្រកាន់យក ដើម្បី រ៉ៀរចាក ការជ្រៀត ជ្រែក នៃ ប្រទេស ចិន មកក្នុង កិច្ចការ ផ្ទៃក្នុងយួន។

ចិន ជា ទ្រឹស្ត្ររបស់ នរណា ?

ឃួន និង ចិន មាន ទស្សនៈ ដូចគ្នា គឺ បាន ដាក់ ប្រទេស របស់ គេ នៅ កណ្តាល ដោយ ប្រៀបធៀបនឹង ប្រជាជន ដទៃ ទៀត ដែល គេ ទុក ជា មនុស្ស ព្រៃ។ គេ បែកចែក ដាច់ ពីគ្នា រវាង ប្រជាជាន ដែល រស់នៅ មាន ចំនួន ច្រើន ឬ តិច ជា អចិន្ត្រៃ យ៍ នៅក្នុង ដែនដី នៅក្រោម ការត្រួតត្រា រដ្ឋបាល និង យោធា ហើយនឹង ប្រជាជន ដែល រស់នៅ ក្រៅ ព្រំដែន របស់គេ។ ដូច្នេះ គេ ទទួលស្គាល់ ថា នៅក្រៅ រាជនគរ របស់គេ វា មាន ប្រព័ន្ធ នយោបាយ មិន ស្ថិតស្ថេរ ក្នុងនោះ មាន អ្នកដឹកនាំ រពឹស ដែល នឹងអាច នាំបង្កើត នូវ ហានិភ័យ ដល់ សន្តិសុខ នៃ តំបន់ ព្រំដែន។ ការប្រាថ្នា របស់ព្រះចៅឃួន ទាំងឡាយ ដើម្បី ភាពខ្ពង់ខ្ពស់ ខាង រឬជម៌ នៅក្នុង ទំនាក់ទំនង ជាមួយ ប្រទេស ជិតខាង ទាំង ខាងលិច និង ខាងត្បូង គឺ សេចក្ដី ជារម្ម ក្នុង ព្រះរាជហឬទ័យ ជានិច្ច ថា ដែនដី ទាំងនោះ មាន ការច្រឡំបល់ ហើយ បង្ហូរ ជារឿយៗ នូវ ការអ័ព្ទអួ ចំពោះ ប្រទេសគេ។ ដូច្នេះ ការត្រួតត្រា ផ្ទៃក្នុង នៃ ដែនដី នៃ រដ្ឋ ពាក់ ព័ន្ធ ដោយ អាទិភាពនឹង សកម្មភាព នៅ ព្រំដែន ដែល អាច ជា ទីកន្លែង អសន្តិសុខ។ អាទិភាព នោះ គឺ ការប្រើ កម្លាំង យោធា ដើម្បី រក្សា សន្តិសុខ តាម ព្រំដែន។ ហើយ ទោះបី នៅ ពេល ដែល ព្រះចៅឃួន ទាំងឡាយ មាន អារម្មណ៍ ថា ខ្លួន មាន ថាមពល ក្រាប់ក្រាន់ នឹងអាចផ្ដល់ នូវ ភ្ជនាទី ដ៏ក្រអឹតក្រទម សំរាប់ ត្រួតត្រា ពិសេស លើ ប្រទេស ជិតខាង ក៏ព្រះអង្គ នៅតែ ទុក តំបន់ ព្រំដែន ជា កន្លែង មាន ភាពតានតឹង និង មាន

ជម្លោះ។ ទស្សនៈ នៃ សន្តិសុខ ផ្ទៃក្នុងយួន គឺ ជា គោលលទ្ធិ ភូមិ សាស្ត្រ នយោបាយ របស់ព្រះចៅយួន។ តាមគោលលទ្ធិ នោះ ទ្រង់ ទុក ដែនដីយួន ស្ថិត នៅក្នុង ការព័ទ្ធ ជុំវិញ នៃ ភ្នំ ទាំងឡាយ ដែល កំណត់ ជាមុន ដោយ មេឃ និង ដី ជា អចិន្ត្រៃ យ៍។ ដូច្នេះ រាជការិយកម្ម របស់ព្រះចៅយួន គឺ ព្រះអង្គ ត្រូវ ធានា ការពារ ដែនដីជាតិ ដែល ជា រាជកាតព្វកិច្ច ទុក ជា អំណាច ស្របច្បាប់ របស់ព្រះអង្គ នៅ ចំពោះមុខ ប្រជាជាតិយួ ន។ ការបោះបង់ចោល នូវ រាជកាតព្វកិច្ច នេះ ទុក ជា ការ លះបង់ សិទ្ធិ ក្នុង ការគ្រប់គ្រង រាជសម្បត្តិ។ ប៉ុន្តែ គោលលទ្ធិ ភូមិសាស្ត្រ នយោបាយ ដែល ចារ នៅក្នុង ក្របខណ្ឌ នៃ សន្តិ សុខ នៃ ព្រំដែនជាតិ នេះ វា ជំរុញអោយ ព្រះចៅយួន ទាំងឡាយ នៅក្នុង គតិ « ការពារ ដ៏ប្រសើរ គឺ ត្រូវ វាយប្រហារ ជា មុន » នគរ ជិតខាង ទាំងឡាយ ណា ដែល មាន អំណាច ជា គូ ប្រជែង ដើម្បី ថែរក្សា ដែនដី ដែល ស្ថិត នៅក្រោម ការ ត្រួតត្រា របស់ព្រះអង្គ, តួយ៉ាង : រានកាន[1] ទឹកដី នគរ ចាម។ នៅឆ្នាំ ១៤៧១ កងទ័ព យួន បាន វាយ ប្រហារ យកបាន រាជ ធានី នគរ ចាម ឈ្មោះ វិជ័យបូរី (Vijaya) ហើយនៅ ឆ្នាំ ១៤៧៩ ក៏ វាយ យកបាន បណ្តាល ខេត្ត នៃ ប្រទេស លាវ មួយចំនួន ហើយ នៅក្នុង សតវត្ស ទី១៧ យួន ក៏ចាប់ផ្តើម រុករានចូល មក ក្នុង ដែនដី កម្ពុជាក្រោម ដែល ទុក ជា ដំណើរ ទៅ ទិស ខាង ត្បូង នៃ ប្រជាជនយួន។ នៅពេល ធ្វើ ការវាយប្រហារ រុករាន

[1] រានកាន : រាតត្បាត, យកដោយរំលោភ។

ចូល ម្តងៗ យួន តែងតែ លើក យក ទស្សនៈ ការចនាចារ្ម (moraliste) ជា ផ្លូវការ នៃ ព្រះចៅចិន ក្នុង ទំនាក់ទំនង កិច្ច ការបរទេស គឺ ការប្រឆាំង រវាង « អ្នកមានអារ្យធម៌ » នឹង « មនុស្សព្រៃ » ដើម្បី រក្សា សន្តិសុខ នៃ ប្រជាជាតិ។ ការរាតត្បាត នៃ ទ័ព យួនកុម្មុយនិស្ត នៅ អំឡុង ឆ្នាំ ១៩៧០-៧៩ គឺ ជា ការ បន្ត អនុវត្ត គោល លទ្ធិភូមិសាស្ត្រ នយោបាយ ពាន់ឆ្នាំ របស់ ព្រះចៅយួន ទាំងឡាយ ដែល ពួក អ្នកដឹកនាំ យួនកុម្មុយនិស្ត យកមក ប្រតិបត្តិ តាម។ ស្រុកខ្មែរ និង លាវ សព្វថ្ងៃ ស្ថិត នៅ ក្រោម ឥទ្ធិពលយួន គឺ ជា ការបកប្រែ សម័យ នៃ គោលលទ្ធិ នេះឯង។ ស្ថានភាព នៃ ការគ្រោបសង្កត់ របស់យួន សព្វថ្ងៃ មាន ការប្តូរ នៅក្នុង ការអនុវត្តន៍ ខុស ពី សម័យដើម តែ ភាពខុសគ្នា វា មិន ស្ថិត នៅក្នុង គោលលទ្ធិ នោះទេ គឺ វា គ្រាន់ តែ ប្តូរ អោយ រីកធំឡើង ទៅតាម កម្លាំង ដែល ខ្លួន មាន សំ រាប់ ធ្វើអោយ សម្រេច បាន។ នៅ ចំពោះមុខ អំពើ នោះ ចិន តែងតែ បិទ ភ្នែក ហើយ ប្រហែល ជា នឹកសប្បាយចិត្ត ចំពោះ មុខ រីរ៉ាត ១ របស់យួន ទៀតផង ព្រោះ យួន ជា មិត្ត មនោគម វិជ្ជា និង ពួជ អំបូរ នឹងខ្លួន។

តាំងតែ ពី ចិន ទទួលស្គាល់ ជា ផ្លូវការ អធិបតេយ្យភាព ស្រុក យួន នៅ ឆ្នាំ ១១៦៤, ហើយ បន្ទាប់ ពី ដំណាក នៃ ទំនាស់ យោធា ដ៏យូរអង្វែង រវាង ប្រទេស ទាំងពីរមក ទំនាក់ទំនង របស់គេ ក៏ ចាប់ មាន ស្ថេរភាព រីកចំរើន បន្តិចម្តងៗ។ ចិន រៀរមិន ធ្វើ អន្តរាគមន៍ លើ នយោបាយ រុករាន របស់យួន ចូល ទៅក្នុង

ចិន ជា មិត្ត របស់ នរណា ?

ប្រទេស ជិតខាង ដូចយ៉ាង ស្រុក ចាម ខ្មែរ និង លាវ ដរាបណា ទង្វើនេះ វា មិន គំរាម ដល់ សន្តិសុខ នៃ ព្រំដែន ចិន។ ជា ការ ពិត ណាស់ ជួនកាល វា មាន ការប៉ះទង្គិច អារុធគ្នា រវាង ឆ្នាំ ព្រំដែន រហូត បង្កើត ជា សង្គ្រាម ដូចយ៉ាង នៅ ឆ្នាំ ១៩៧៩[2] តែ ជា សង្គ្រាម នៅក្នុង ក្រឡាដីតូច ហើយ នៅ ទីបញ្ចប់ តែងតែ មាន ដំណោះស្រាយ តាម សន្និវិធី នៅក្នុង ក្របខណ្ឌ ញាតិវប្ប ធម៌ ព្រោះ ថា ប្រទេស ទាំងពីរ គេ មាន វប្ប ធម៌, ប្រពៃណី រដ្ឋ បាល និង ចិត្តគំនិត នយោបាយ តែមួយ ច្រើន សហស្សវត្សរ៍ មកហើយ។ ពួកគេ រមែង កោតសរសើរ និង គោរពគ្នា ទៅវិញ ទៅមក។ ស្រុកចិន កុម្ម្ងយនិស្ត ទុក ស្រុកយួន ជា ប្រទេស កុម្ម្ងយនិស្ត ដ៏ប្រសើរ ហើយ ជា ប្រជាជាតិ ចាស់ទុំ មាន សមត្ថ ភាព គ្រប់គ្រាន់ ចេះ ការពារ អធិបតេយ្យភាពជាតិខ្លួន ពី ការ ឈ្លានពាន ពី សំណាក់ អធិរាជ ចិន, អាណានិគម បារាំងសែស និង ចក្រពត្រ អាមេរិកាំង។ រីឯ យៀកណាម វិញ សំឡឹងមើល ទៅ ប្រទេស ចិន ដោយ មាន ការព្ងួយបារម្ភ ផង និង ការ ក្រែងរអែង ផង។ ការព្ងួយបារម្ភ ពី ព្រោះ នគរខ្លួន មាន ព្រំ ដែន រួម ជាមួយ ប្រទេស មហាអំណាច សេដ្ឋកិច្ច នៅក្នុង ពិភពលោក និង មាន ចំនួន ប្រជាជន ជាង មួយ កោដិ នា ក់។ ការគោរព ព្រោះ ខ្លួន តែងតែ ទុក ចិន ជា គំរូ សំរាប់ខ្លួន

[2] ចិន វាយ យួន ដើម្បី បង្ហាញ នូវ បដិយោគ របស់ចិន ពី ការវាយប្រហារ កងទ័ពយួន ចូល កាន់កាប់ ស្រុកខ្មែរ នៅក្រោម ការដឹកនាំ នៃ របប ខ្មែរក្រហម ដោយ យក ជម្លោះ ព្រំដែន ជា លេស។

ហើយ ជា អ្នកការពារ ដោយ គ្មានលក្ខណ ដល់ ប្រជាជនយួន ក្នុង ការតស៊ូ ដើម្បី ឯករាជ្យជាតិ ប្រឆាំងនឹង ការត្រួតត្រា របស់លោកខាងលិច។ ជានិច្ច ចិន និង យួន មាន មូលហេតុ តែមួយ គឺ ការការពារ នៃ លទ្ធិកុម្មុយនិស្ត នៅ ក្នុង អាស៊ី ដែល កំពុង ជួបប្រទះនឹង ការគំរាម ពី សំណាក់ លទ្ធិប្រជាធិបតេយ្យ ឈានឫទ្ធិ។ ដូច្នេះ គេ សន្ធត់ ថា ប្រទេស ទាំងពីរ ត្រូវតែ ស្ថិត នៅ ជា មិត្ត ប្រវត្តិសាស្ត្រ នឹងគ្នា ជា និច្ច ទោះបី មាន ទំនាស់ នឹងគ្នា នៅក្នុង កិច្ចការ នយោបាយ ការបរទេស ដូចយ៉ាង ការ ងាក របស់ យួន ទៅជិតនឹង សហរដ្ឋអាមេរិក។ តែ បើ គេ តាម ដាន នយោបាយ របស់យួន បន្តិច គេ ឃើញ ថា ហាណូយ តាំង ពី សង្គ្រាម លើកទី១ នៅ ឥណ្ឌូចិន មកម្លេះ គេ តែងតែ ស្វែង រក កូនប្រយោល នៅក្នុង ទំនាក់ទំនង របស់ខ្លួន ជាមួយ ចិន ដែល ជា មហាអំណាច និង ញ្ញាតិវប្បធម៌ រួម ទោះបី យួន ស្វែង រក ស្រប នូវ ការគាំទ្រ ពី សហភាពសូវៀត ព្រោះ ពេលនោះ យួន ត្រូវការពាំនឹង ដ៏ធំមួយ ពី សំណាក់ លោកកុម្មុយនិស្ត។ ជម្រើស នេះ វា គ្មាន រ៉ាន អ្វី ដល់ ចិន នោះឡើយ, ផ្ទុយទៅវិញ ចិន តែងតែ លើក ទឹកចិត្តយួន ដែល ជា ឬន រួមវប្បធម៌ ១សេព គប់ ជាមួយនឹងប្រទេស ទាំងឡាយ ដែល ទុក អាមេរិកាំង ជា សត្រូវ និង មាន ទំនាក់ទំនង ជា នយោបាយ ទូត នឹងខ្លួន ដើម្បី ជួយ ដល់ យួន។ តែ នៅពេល សង្គ្រាម ផ្ទុះឡើង នៅ ស្រុក ខ្មែរ នៅ ឆ្នាំ ១៩៧០ ក្រោយ ពី ស្តេចសីហនុ ត្រូវ គេ ទម្លាក់ ពី អំណាច វា មានទំនាស់ កើតឡើង រវាង ចិន និង យួន ក្នុង

ចិន ជា មិត្ត របស់ នរណា ?

ជម្រើស ជួយ ដល់ ពួក ខ្មែរក្រហម ដើម្បី ច្បាំង ប្រឆាំងនឹង សារ ធារណរដ្ឋខ្មែរ។ ចិន មាន គោលបំណង ចង់ឲ ការតស៊ូ អាវុធ របស់ ពួក ខ្មែរក្រហម មាន ស្វ័យភាព ពេញលេញ ចំពោះ កងទ័ព រំដោះយួន តែ ហាណូយ វិញ មិន ស្របនឹង ការចង់បាន របស់ចិន នេះឡើយ, យួនកុម្មុយនិស្ត គេ ចង់ បញ្ចូល កងទ័ព តស៊ូខ្មែរ នៅក្នុង យុទ្ធសាស្ត្រយួន តែមួយ នៅក្នុង សមរភូមិ យោធា នៅ តណ្ណូចិន ដែល មាន យួន ជា មេបញ្ជាការ តែមួយ លើ ទ័ពតស៊ូ យួន ខ្មែរ និង លាវ។ បន្ទាប់ ពី ចុះហត្ថលេខា កិច្ច ព្រមព្រៀង សន្តិភាព រវាង យៀកណាម និង សហរដ្ឋអាមេរិក នៅ ទីក្រុង ប៉ារីស នៅ ថ្ងៃ ទី២៧ មករា ឆ្នាំ ១៩៧៣ យួនកុម្មុយ និស្ត អនុញ្ញាត អោយ បក្ស ខ្មែរក្រហម ដឹកនាំ នយោបាយ ត ស៊ូយោធា ដោយ ខ្លួនឯង ប៉ុន្តែ យួន គេ នៅ រក្សា កងទ័ព របស់ ខ្លួន នៅ ស្រុកខ្មែរ ដើម្បី បន្ត ធ្វើ សង្គ្រាម ប្រឆាំងនឹង យៀក ណាម ខាងត្បូង។ ដូច្នេះ មតិភេទ រវាង ចិន និង យួន ក៏បាន ដោះស្រាយ រួចស្រេច។ តែ ក្រោយ ពី បក្ស ខ្មែរក្រហម មាន ជ័យ ជំនះ នៅ ឆ្នាំ ១៩៧៥ ចិន ជា អ្នក មានអំណាច ដាច់មុខ នៅ ស្រុកខ្មែរ ដែល ជា ទីកន្លែងមួយ ដែលសេរីភាព គ្រប់ បែប យ៉ាង ត្រូវ តែ កំទិច ចោល ដោយ អំណាច អាវុធ។ បក្សកុម្មុយ និស្តខ្មែរ ចិនូបនីយកម្ម បាន ប្រព្រឹត្ត អំពើ ប្រល័យ ពូជសាស ន៍ ដែល នាំអោយ ប្រជាជនខ្មែរ បាត់បង់ ជីវិត ជិត ពីរ លាន នាក់។ ដូច្នេះ ចិន ជា អ្នកទទួលខុសត្រូវរួម នៅក្នុង វិនាសកម្ម អមនុស្សធម៌ នៃ ប្រជាជាតិខ្មែរ។

ឧប សៅ សង្ហា **ការសាកល្បង** **១ មីនា ២០២០**

ក្រោយ ពី យួនខាងជើង មាន ជ័យជំនេះ លើ យួនខាងត្បូង, ហាណូយ សម្រេចចិត្ត ដកទ័ព ចេញ ពី ស្រុកខ្មែរ។ ប៉ុន្តែ ការដកទ័ព នោះ គឺ ធ្វើ តាម ផែនទី ដែល យួន ជា អ្នកក្រោយ បន្ទាត់ព្រំដែន មិនមែន យក ផែនទី ដែល អន្តរជាតិ ទទួល ស្គាល់ ស្រុកខ្មែរ នោះឡើយ។ អាស្រ័យហេតុ នេះ ក៏បង្កើត ជា ជម្លោះ ព្រំដែន រវាង យៀកណាម បង្ហូរបង្ហូម តែមួយ និង កម្ពុជា ប្រជាធិបតេយ្យ។ ជម្លោះ នេះ នាំ បង្ក ជា សង្គ្រាម ដែល យួន ជា អ្នកឈ្នះ ហើយ កាន់កាប់ ដោយ យោធា ស្រុកខ្មែរ អស់ រយៈ ពេល ១០ ឆ្នាំ។ ទង្វើ នេះ ធ្វើ១ ចិន មាន ការភ្ញាក់ផ្អើល នៅ ចំពោះមុខ ភាពមោះមុត និង ជោគជ័យ ឆាប់រហ្ស ១ របស់យួន មកលើ ខ្មែរក្រហម ដែល មាន ខ្លួន ជា អ្នកការពារ។ ត្រូវដឹង ថា នៅពេលនោះ ចិន គ្មាន លទ្ធភាព អ្វី បន្ទិច សោះឡើយ ដើម្បី ការពារ ស្រុកខ្មែរ ដែល ជា នគរ ចុះ ទុនខ្សោយ ដោយសារ អនុ វត្ត នយោបាយ ប្រល័យពូជសាសន៏។ ហើយ គេ ដឹង ថា បើ គ្មាន សហគម អន្តរជាតិ ផ្តន្ទាទោស ដល់ ការឈ្លានពាន ១ របស់ យោធាយួន មកលើ ស្រុកខ្មែរ វា ច្បាស់ ជា គ្មាន ការតស៊ូខ្មែរ ប្រឆាំងនឹង យោធាយួន នៅតាម ព្រំដែន ខ្មែរ-ថៃ នោះឡើយ។ ហើយ បើ គ្មាន ការដួលរលំ នៃ សហភាពសូវៀត វា ក៏ច្បាស់ ណាស់ដែរ ថា វានឹង គ្មាន ការដកទ័ពយួន ចេញពី ស្រុកខ្មែរ ងាយៗស្រួល ១ ១ ដែរ។ នៅក្នុង ស្ថានភាព នេះ ខ្ញុំ អាច សួរ ជា សំនួរ ថា ក្រាប់ បញ្ហាខ្ញុំ ដែល មាន រវាង ចិន និង យួន តើ ជា

ឧបសគ្គ ចម្បង នៃ ទំនាក់ទំនង ជា ញាតិ ជា មិត្ត ប្រវត្តិសាស្ត្ររវាង ប្រទេស ទាំងពីរ នោះដែរ ឬទេ ?

ចិន ជា មិត្ត របស់ ខ្មែរ ?

ត្រូវ យើង សង្កេត អំពី ឥរិយាបថចិន ចំពោះ ស្រុកខ្មែរ ចាប់ ពីឆ្នាំ ១៩៥៥ រហូត មកដល់ ឆ្នាំ ១៩៩៣។ ភាពស្ងិតស្ងុន់ តូចៗ ជាច្រើន របស់សកម្មភាពចិន មកលើ ខ្មែរ បង្ហាញ នូវ មារយាទ លាក់មុខ របស់ចិន នៅក្នុង ទំនាក់ទំនង ជាមួយ យួន ដែលតែងតែ ហុច ប្រយោជន៍ ដល់ យួន ជា និច្ច។ នៅក្នុង ទស្សវត្ស ៦០ លោក ជូ អេងឡាយ ជា រដ្ឋមន្ត្រីទី១ ចិន នៅពេលនោះ តែងតែ ផ្តល់ ដំបូន្មាន ដល់ សម្តេច សីហនុ ដើម្បី រក ប្រយោជន៍ ឱ្យ យួនកុម្មុយនិស្ត ដូចយ៉ាង ការបោះបង់ចោល ជំនួយសេដ្ឋកិច្ច និង យោធា របស់សហរដ្ឋអាមេរិក តែ ចិន ក៏មិន បានទូទាត់ សង ជា សមាមាត្រ សំរាប់ ការបាត់បង់ នៃ ប្រយោជន៍ខ្មែរនោះ ដែរ ដែល នាំអោយ ខ្មែរ បាត់ បង្អែកយោធា នៅ ចំពោះមុខ កងទ័ព កុម្មុយនិស្តយួន នៅ ឥណ្ឌូចិន។ សម័យ នៃ រស្មីចិន នៅ ស្រុកខ្មែរ សម្តេច សីហនុ បាន អនុវត្ត នយោបាយ សេដ្ឋកិច្ច បែប សង្គមនិយម តែ ក្រោយ បន្ទាមក រាជដម្រើស នេះ បាន នាំអោយ សេដ្ឋកិច្ច ធ្លាក់ ទៅក្នុង ភាពក្សោយទន់ ដែល នាំអោយ ស្រុកខ្មែរ ដែល មាន មធ្យោបាយ ត្រប់ត្រាន់ល្អ ក្លាយ ជា ស្រុក ក្រាំង យន្តកម្ម នៃ ការអភិវឌ្ឍន៍ ហើយ ក្លាន ទស្សនៈ:វិស័យ សំ រាប់ អនាគត។ មួយវិញទៀត ព្រះអង្គ ពាយដាយ នឹង ការ

ចិន ជា មិត្ត របស់ នរណា ?

ពង្រីក និង ការពង្រឹង កងទ័ពជាតិខ្មែរ នៅក្បែរ សង្គ្រាម នៅ ស្រុកយួន ហើយ នៅពេល ដែល កងទ័ពថៃ និង យួន ទាំងពីរ គេរៀបចំ ទំនើបកម្ម។ មិន តែ ប៉ុណ្ណោះ លទ្ធិប្រជាធិបតេយ្យ ត្រូវបាន សម្តេច សីហនុ ក្រវែងចោល ទៅក្នុង ធុងសំរាម ដើម្បី អាចអោយ លទ្ធិផ្តាច់ការ មាន រស្មី ដែល នាំអោយ បាត់ ការ រួបរួមជាតិខ្មែរ។ ដូច លោក Stefan Zweig សរសេរក្នុងសៀវភៅ របស់លោក មាន ចំណងជើង « សតិសម្បជញ្ញៈ នៃ ហិង្សា » : « វា ត្រូវ មាន រយៈពេល យូរ បន្ទិច មុននឹង ប្រជាពលរដ្ឋ ចាប់ ដឹង ខ្លួន ថា ផលប្រយោជន៍ មួយរយៈ ដែល អំណាចផ្តាច់ការ ផ្តល់ ឱ្យខ្លួន នៅក្នុង វិនិយ តឹងរឹង និង កម្លាំង អំណាច ពង្រឹង ត្រូវ ទុក ជា ការប្តូរនឹង ពលិកម្ម របស់ ប្រជាពលរដ្ឋ ដែល ត្រូវ បោះបង់ សិទ្ធិបុគ្គល ហើយ រាល់ ច្បាប់ ថ្មី ដែល របប ផ្តាច់ការ បង្កើតឡើយ វា តែងតែ ហូត តម្លៃ នៃ សេរីភាពដើម នៃ មនុស្ស ជា ការចាំបាច់ »។

ចាប់ពី ឆ្នាំ ១៩៦៨ ស្រុកខ្មែរ ក្លាយ ជា ស្រុកពិការ។ សេដ្ឋកិច្ច ជាតិ ជួបប្រទះ នូវ វិបត្តិ ជាជម្រៅ ហើយ ស្រុកខ្មែរ ត្រូវ បាន កង ទ័ព យួនកុម្មុយនិស្ត មាន ចំនួន ប្រមាណ ៦ ម៉ឺន ៥ សែន នាក់ ចូល កាន់កាប់។ តើ ត្រូវ ធ្វើ ដូចម្តេច ? នៅលើ សំនួរ នេះ ស ម្តេចសីហនុ ទ្រង់ ទទួល សារភាព ដោយ ខ្លួនឯង ថា : « កំហុស មួយ ដែល ខ្ញុំ មិនគួរ ធ្វើសោះ គឺ បដិសេធ ជំនួយ អាមេរិកាំង, ទ្រង់បន្ថែមថា បើ ខ្ញុំ មាន ឱកាស អាចនឹង ធ្វើឡើងវិញបាន គឺ ខ្ញុំ មិនបោះបង់ ជំនួយ នេះឡើយ, ការផ្តាច់ ទំនាក់ទំនង

ជាមួយ អាមេរិកាំង គឺ ជា ក្រោះថ្នាក់ ដ៏ធំ បំផុតសំរាប់ខ្លួនខ្ញុំ ផ្ទាល់ និង សេដ្ឋកិច្ចជាតិ »។ តែ ការទទួលស្គាល់ កំហុស នោះ វា ក្រាន់ តែ កបិចិត្ត (caprice) ជា ធម្មជាតិ របស់ ព្រះអង្គ តែ ប៉ុណ្ណោះ ព្រោះ ថា ទ្រង់ មិន ក្រាន់តែ មិន រលាស់ កំហុស ពី ចិត្ត ផ្ទុយទៅវិញ ទ្រង់ រីងរឹតតែ ពង្រីក និង ពង្រឹង មិត្តភាព ជា មរណ: ជាមួយ យួន និង ចិន ក្បួយនិស្ត ដែល នាំអោយ ប្រជាជាតិខ្មែរ ធ្លាក់ ចូល ទៅក្នុង សំណាញ់ ចិន និង យួន ហើយ វា រួត កម្ពុជា រហូត មកដល់ សព្វ ថ្ងៃ នេះ។

តែ នៅក្នុង អំណាច ផ្តាច់ការ ដែលមាន សម្តេច សីហនុ ជា អ្នក ដឹកនាំ ប្រជាជនខ្មែរ គាត់ ក្ខាន ជម្រើស អ្វី ក្រៅពី គោរពគោល នយោបាយ របស់ព្រះអង្គ ពុំនោះ សោធ ត្រូវ សម្តេច ចោទ ប្រកាន់ ថា ជា ជនក្បត់ជាតិ ដូចយ៉ាង ករណី លោក សម សារី និង សឹង ង៉ុកថាញ់ ដែល ក្រាន់ តែ ពួកគាត់ មាន គំនិត នយោបាយ ខុស ពី ព្រះអង្គ តែ ប៉ុណ្ណោះ។ តែនៅ ឆ្នាំ ១៩៧០ មាន រះ:ជន និង យុវបញ្ញាវន្ត មួយចំនួន មិនសុខចិត្ត នៅទ្រាំ មើល អំពើ បំផ្លាញ ជាតិ របស់សម្តេចសីហនុ ក៏នាំគ្នា រសាយ ជំនឿ លើ របប សង្គមរាស្ត្រនិយម រ៉ុញប៉ខុញ[3] ហើយ ដើប ប្រឆាំងនឹង ព្រះអង្គ ដែល ជា ប្រតិកម្ម សយម្ភូត[4] នាំ បង្កើត ព្រឹត្តិការណ៍ ថ្ងៃទី ១៨ មីនា ដែល ជា ថ្ងៃ ដែល ត្រូវ បាន សកាទាំងពីរ របស់ ប្រជាជាតិខ្មែរ ចោះឆ្នោត ទម្លាក់ ព្រះអង្គ ពី

[3] រ៉ុញប៉ខុញ : ដែលរេចរឹលខិញ្ញរខុក។សំ
[4] សយម្ភូត : ដែលធ្វើដោយឯកឯង, spontanée។

តំណែង ប្រមុខរដ្ឋ។ រី ចិន នៅពេល នោះ បានធ្វើ សកម្មភាព ក្រាប់ បែបយ៉ាង ដើម្បី រុញ សម្តេច សីហនុ ឱ្យ ចេញមុខ ប្រឆាំង នឹង សេចក្តីសម្រេច នៃ សភាជាតិខ្មែរ ដោយ ធានា ថា កងទ័ព យួនកុម្មុយនិស្ត តាំង នៅក្នុង ស្រុកខ្មែរ គេនឹង រាយប្រហារ កងទ័ពជាតិខ្មែរ ដើម្បី យកអំណាច មក ប្រគល់ថ្វាយ ព្រះអង្គ វិញ ឱ្យទាល់ តែបាន។ ការណ៍នេះ ជាហេតុ នៃ សង្គ្រាម កើតមាន ឡើង នៅ ស្រុកខ្មែរ នៅពេលនោះ។ នៅក្នុង សម័យ សាធារណ រដ្ឋខ្មែរ (១៩៧០-១៩៧៥) ដែល ជា របប ការពារ បូរណភាព ទឹក ដីខ្មែរ ចំពោះមុខ ការឈ្លានពាន ដោយ កម្លាំង អាវុធ ពី សំណាក់ យួនកុម្មុនិស្ត ប៉ុន្តែ នៅក្នុង សង្គ្រាម ការពារខ្លួន នោះ ប្រទេស ចិន គាំពារ យ៉ាង ម៉ឹងម៉ាត់ ការឈ្លានពាន របស់យៀ កកុង ដូចយ៉ាង បង្កើត រណសិរ្ស រួបរួម ជាតិខ្មែរ ដែលមាន កង ទ័ពយៀកកុង ពាក់ ឯកសណ្ឋាន ជា ខ្មែរ ធ្វើ ជា ទ័ព របស់រណ សិរ្សខ្មែរ, កែក្រម្ទៃ សង្គ្រាម ឈ្លានពាន ពី សំណាក់បរទេស ១ក្លាយ ជា សង្គ្រាមស៊ីវិល។

នៅក្នុង កិច្ចព្រមព្រៀង សន្តិភាព នៅឥណ្ឌូចិន ថ្ងៃ ទី២៧ មករា ឆ្នាំ ១៩៧៣ ចិន បញ្ជា អោយ ពួក ខ្មែរក្រហម បដិសេធ ដាច់ ខាត មិនព្រម អោយ ចុះហត្ថលេខា ដើម្បី បន្ត សង្គ្រាម រវាង ខ្មែរ និង ខ្មែរ គឺ ថា រវាង ពួក ខ្មែរក្រហម និង ខ្មែរសាធារណ:រដ្ឋ នៅក្នុង គោលដៅ តែមួយ គត់ គឺ បន្ត ទុក ទឹកដីខ្មែរ ជា សមរ ភូមិ គាំទ្រ ការវាយប្រហារ របស់យួនកុម្មុយនិស្ត ទៅលើ យួន ខាងត្បូង ជាយួនសេរី ដោយ បំពាន លើ កិច្ចព្រមព្រៀង សន្តិ

ភាព ដែល ខ្លួន បានយល់ព្រម ចុះហត្ថលេខា ជាមួយនឹង អាមេ រិកាំង។

សេចក្តីសន្និដ្ឋាន

បើ យោង ទៅលើ អំពើ ក្រាប់ បែបយ៉ាង ដែល បាន រៀបរាប់ ខាងលើ នេះ យើង អាច សន្និដ្ឋាន បាន ថា ចិន និង យួន កុម្មុយនិស្ត ពិត ជា មិត្តល្អ របស់ សម្តេច សីហនុ តែ ជាទ្រុស្តមិត្ត របស់ប្រជាពលរដ្ឋខ្មែរ។ សុំ ខ្មែរ ម្នាក់ៗ រិះមើល ទាល់តែឃើញពិត ដោយ ខ្លួនឯងចុះ ព្រោះថា វិភាគ របស់យើង នេះ វា ក្រាន់តែ ជា វិស័យមតិ មួយ ក្នុងជំនឿ ជាក់ច្បាស់ ថា ចិន និង យួន កុម្មុយនិស្ត វា ជា បញ្ហារបស់ ប្រជាជាតិខ្មែរ តាំងពី ទសវត្សរ៍ ទី ៦០ រហូត មកដល់ សព្វថ្ងៃ នេះ។

ចិនកុម្មុយនិស្ត បន្ត ជួយ ពួក ខ្មែរក្រហម ក្រោយ ពី របប ប្រល័យពូជសាសន៍ នេះ ដួលរលំ រត់ ទៅ រក រស់ តាម ព្រំដែន ខ្មែរ/ថៃ។ បន្ត ធ្វើ សង្គ្រាម ក្នុងនាម ជា សង្គ្រាម តស៊ូ រំដោះជាតិ នាំ បន្សាប កម្លាំងតស៊ូ របស់អ្នកស្នេហាជាតិខ្មែរ នៅ ចំពោះ មុខ ប្រជាជនខ្មែរ រស់ នៅក្រោម របប អាណានិគមយួន។ ការ រក្សា អង្គការ ខ្មែរក្រហម នៅក្នុង ចលនាតស៊ូខ្មែរ ជា គំនិត ខុស មួយ ចំពោះ អ្នកស្នេហាជាតិខ្មែរ តែ ចិន គេ យល់ ផ្ទុយ ទៅ វិញ ថា ជា កម្លាំងប្រាកដ របស់ ជាតិខ្មែរ ដែល អាច យក ឈ្នះ យួន បាន។ ត្រូវដឹង ថា កម្លាំង នេះឯង ភាគច្រើន ដាច់ខាត នាំ គ្នា ចុះ ចូល ហ៊ុន សែន បន្ត ធ្វើ សកម្មភាព សម្លាប់ ប្រជា

ពលរដ្ឋខ្មែរ ក្នុង យុទ្ធសាស្ត្រ យួន/ចិន ដើម្បី រក្សា លទ្ធិកុម្មុយនិស្ត នៅ ស្រុកខ្មែរ។

កិច្ចព្រមព្រៀងសន្តិភាព ថ្ងៃ ទី២៣ តុលា ឆ្នាំ ១៩៩១ ជា ដំណោះ ស្រាយ នៃ វិវិធ របស់ ចិន-យួន ក្នុង ការដណ្តើមយក កម្ពុជា មកដាក់ នៅក្នុង ឥទ្ធិពល របស់ខ្លួន។ ពី ដើម ចិន ចង់បាន កម្ពុជា ដើម្បី ទប់ទល់ យួន រីឯយួន ចង់បាន ដីខ្មែរ មក ធ្វើ ជា ដីយួន។ តែ នៅពេល ដែល ចិន និង យួន គេ រកឃើញ រូបមន្ត រួមគ្នា គឺថា ចិន ជា អ្នក យក ធនធាន ធម្មជាតិខ្មែរ និង ជា ធានាគារ សំរាប់ របប ផ្តាច់ការ ខ្ជិ លុយ រីឯ យួន យក ដីខ្មែរ ជា ដី សម្បទាន សំរាប់ ចិញ្ចឹម សេដ្ឋកិច្ចយួន។ ហើយ ចិន-យួន គេ រកស៊ី ជាមួយគ្នា លើ ខ្នងខ្មែរ ចែក ជា ក២ម្រ ខ្លះ ១ ពួក សម្តេច និង ពួក នាម៉ឺនខ្មែរ ដើម្បី ១ដើរ ហឺហារ ធ្វើ ជា អ្នកមាន ពាក់ ងារ សក្តិភូមិ ក្នុង ភ្ជួនាទី ជា ភ្ជួឯកល្ងោន ហ៊ី របស់ចិន និង កែ លឿង របស់យួន។ យួន ប្រើ កិច្ចព្រមព្រៀង ២៣ តុលា ជា មធ្យោបាយ សំរាប់ ពង្រឹង អំណាច របប ដឹកនាំ សព្វថ្ងៃ ដែល ជា របប អាយ៉ង របស់យួន ដើម្បី ត្រួតត្រា ស្រុកខ្មែរ, ចំណែក ចិន ប្រើ កិច្ចព្រមព្រៀង នោះ ជា ពាណិជ្ជកម្ម រវាង យួន និង ចិន, រី ឯ ពួក មស្ចឹម ប្រទេស ទុក វា ជា ករណីយកិច្ច សីលធម៌ របស់ ខ្លួន តែប៉ុណ្ណោះ, ធ្វើចប់កាលណា នាំគ្នា ដើរចេញ ទុក១ ប្រជា ពលរដ្ឋ ខ្មែរ រស់ ក្ខាន ក្តីសង្ឃឹម នៅក្នុង កិច្ចព្រមព្រៀង ក្រោម តុ របស់ ចិន/យួន ប្ជូ រូប ស្រុកខ្មែរ ១ទៅ ជា ហានសួគ៌ សំរាប់ ថៅកែ ឬ ឧកញ៉ា និង ពួក ជនពុករលួយ មួយក្តាប់ តែ ជា ហាន

ចិន ជា មិត្ត របស់ នរណា ?

នរក សំរាប់ប្រជាជនខ្មែរ មួយនការ។ ពិតប្រាកដ ណាស់ហើយ ថា សហរដ្ឋអាមេរិក ក្តី សហគមអឺរ៉ុប ក្តី នាំគ្នា ឧបត្ថម្ភ ប្រជាពលរដ្ឋខ្មែរ តាម ជំនួយ សេដ្ឋកិច្ច ដូចយ៉ាង វិធាន ការអនុគ្រោះ ពន្ធ, ផែនការ នៃ ការអភិវឌ្ឍន៍ជាតិ និង កម្មវិធី នៃ ការបំពាក់ស្មារតី នៃ លទ្ធិប្រជាធិបតេយ្យ សេរី, សិទ្ធិ នៃ ប្រជាពលរដ្ឋ និង សិទ្ធិមនុស្ស តែ មាន ភាពធូលុង នៅ ចំពោះមុខ ការបំពានគ្រប់ បែបយ៉ាង ពី សំណាក់ គណបក្សប្រជាជន ជា គណបក្ស កាន់អំណាច ក្របដណ្ដប់ ដោយ ស្មារតី ផ្ដាច់ការ។ ថ្មីៗនេះ នៅ ខែ តុលា ហ៊ុន សែន និង រដ្ឋមន្ត្រីទី១ យួន Nguyen Xuan Phuc បាន ចុះហត្ថលេខា ទទួលស្គាល់ ការ ចោះ បង្ហោលព្រំដែន ៨៣% តាម បណ្ដោយ ព្រំដែន ខ្មែរ-យួន, សួរ ថា មហាចិន ដែល មានខ្មែរ ខ្លះ មាន ជំនឿ ថា ហ៊ុន សែន ធ្វើ នយោបាយ ងាក ទៅរកចិន ដើម្បី ការពារខ្មែរ តើ ការការពារ នោះ វា មាន នៅត្រង់ណា ទៅ នៅ ចំពោះ ការ ចុះ ហត្ថ លេខា នេះ ?

ខ្មែរ ត្រូវ រួសរក ដំណោះស្រាយ ដោយ ខ្លួនឯង អោយ ទាន់ កាលវេលា ទើប ប្រជាជាតិ ខ្មែរ ចាកផុត ពី កម្មវាសនា ដូច កម្ពុជាក្រោម ដែល ចិន និង យួន គេ រួមគ្នា ផ្ដាច់ ចេញ ពី ដែនដី ខ្មែរ សំរាប់ ចែកគ្នា រស់នៅ។

សហការ ចិន និង យួន នៅ កម្ពុជាក្រោម

រឿង ដែល ខ្មែរ ត្រូវដឹង ហើយ ចងចាំទុក គឺ: នៅ ក្នុង រដ្ឋការ ព្រះចៅយួន ព្រះនាម Thai-tôn នៅ ឆ្នាំ ១៦៨០ មាន នាយ ឧត្តមសេនីយចិន នៃ ខេត្ត Canton ឈ្មោះ Diuong-ngan-nghich និង ឧត្តមសេនីយ បី រូបទៀត ដែល នៅ ក្រោម បញ្ជា របស់គាត់ មាន ឈ្មោះ Huynh-thanh, Trang-tang-tai និង Tran-an-binh នាំ ទ័ព ចំនួន បី ពាន់ នាក់ ចុះ សំពៅ ចំនួន ៥០ ទៅ ៦០ មក ចត នៅ កំពង់ផែ Tourane ក្នុង ដែនទឹកយួន ដើម្បី សុំ ជ្រកកោននឹង ព្រះចៅយួន។ ឧត្តមសេនីយ ទាំង នោះ ជា អ្នកបំរើ ស្មោះត្រង់នឹង សន្តតីរង្ស Ming នាំ គ្នា រត់ ចេញ ពី ស្រុកចិន ព្រោះ មិន ព្រម ចំណុះនឹង សន្តតីរង្ស ថ្មី ឈ្មោះ Tsing ដែល ជា ពួក Tartares ។

ព្រះចៅយួន មាន ការបារម្ភ ជា ខ្លាំង ក្នុង ជម្រើស យកខាង ណាមួយ ព្រោះ វា ជា បញ្ហា ផ្ទៃក្នុង របស់ចិន, ប៉ុន្តែ ព្រះអង្គ ក៏ មិនហ៊ាន បដិសេធ ដល់ ពាក្យសុំ របស់ ពួក ឧត្តមសេនីយ ចិន ដែល បាន បង្ហាញ ការស្មោះត្រង់ពិត របស់ ពួកគេ ចំពោះ ព្រះ ចៅចិន ដែល ខ្លួន ធ្លាប់ បំរើ ទោះបី ព្រះអង្គ ជា អ្នកចាញ់ ក៏ ដោយ។ ដូច្នេះ ព្រះចៅយួន មាន ព្រះហឫទ័យ ថា នៅក្នុង ទឹក ដី កម្ពុជាក្រោម មាន តំបន់ ជាច្រើន ដែល ព្រះអង្គ មិន ទាន់ បាន កាន់កាប់ នៅឡើយ។ យល់ឃើញ ដូច្នេះ ព្រះអង្គ ក៏ អនុញ្ញាត អោយ ពួក ចិនភៀសខ្លួន ទាំងនោះ ទៅ រស់នៅ នៅ

ក្នុង ដំបន់ ទាំងនោះ។ ចំពោះ ព្រះចៅយួន ចំណាត់ការបែបនេះ នាំអោយ បានចំណេញ ពិសេស បី យ៉ាង ដល់ ស្រុកយួន : ការបន្ថយ ការវាយលុក ចូល ទៅ ក្នុង ទឹកដីខ្មែរ, ការនារាស នៃ ប្រជារាស្ត្រខ្មែរ ចេញ ពី តំបន់ នោះ និង ដោះស្រាយ បញ្ហា ជនភៀសខ្លួនចិន។ ដំបន់ ដែល ព្រះចៅយួន ជ្រើសរើស អោយ ចិន ទៅរស់នៅ គឺ Don-naï (ចង្វាក្រពាំងស្រកាត្រី)។ ព្រះចៅយួន បាន ធ្វើ ចុតហ្ការ ថ្វាយ ដល់ ហ្លួងខ្មែរ ដើម្បី ថ្វាយ ដំណឹងនេះ ព្រោះ នៅពេល នោះ ស្តេចខ្មែរ ព្រះអង្គ នៅក្រោម ឥទ្ធិពលយួន ដោយសារ ព្រះអង្គ ពឹងពាក់ យួន អោយ ជួយ ច្បាំង នៅ ក្នុង សង្គ្រាម ស៊ីវិលខ្មែរ។

ឧត្តមសេនីយ Dioung ទទួលបាន ការអនុញ្ញាត ពី ព្រះចៅយួន ហើយ ក៏ ប្រញាប់ប្រញាល នាំ ទព័ រៀបស់ខ្លួន ចុះ សំបាន និង ទុកប៉ុកចាយ ឬ សំពៅ ធ្វើ ដំណើរ តាម ផ្លូវទឹក ភ្ជ នៃ Mi-tho (មេស-កោះគោង) ឆ្ពោះ ទៅ កាន់ ទីដៅ។ ឯ ចំណែក ឧត្តមសេនីយ Tran និង កងពលធំ របស់គាត់ ចាកចេញ ពី កំពង់ដែ Can-gio សំដៅ ទៅ ដំបន់ ចង្វាក្រពាំងស្រកាត្រី ហើយ នាំគ្នា ជ្រើសយក កន្លែង មួយ ឈ្មោះ Ban-lân ធ្វើ ជា ទីលំនៅ ដើម្បី ប្រកប របរ កសិកម្ម និង ពាណិជ្ជកម្ម។ ទីនោះ ក៏ ក្លាយ ជា ទី ប្រជុំជន ពាណិជ្ជកម្ម សកម្ម ណាស់ ហើយ ជនជាតិចិន រស់នៅ ទីនោះ បាន ហៅរក ចិន ដីគោក ឱ្យ មក រស់នៅ ទីនោះ ដ៏ ច្រើន កុះករ។ បន្ទាប់មក មាន ជន ជាតិអឺរ៉ុប ជប៉ុន និង ជ្វា មក រស់នៅ លើ កប៉ាល់សមុទ្រ រៀងៗខ្លួន នៅ ទីនោះដែរ ដើម្បី

ធ្វើ ពាណិជ្ជកម្ម។ ដូច្នោះ បាន ជា ប្រពៃណី និង ទំនាមទំលាប់ ចិន មាន នៅទី នោះ រហូតមក។ ហើយ នៅ ទីកន្លែង ឈ្មោះ Dong-pho ចិន បាន រៀបចំ ជា ទីក្រុង អោយមាន ទិដ្ឋភាព ល្អ ដូច ទីក្រុង នៅ ស្រុកចិន[5]។

ឧបសម្ព័ន្ធ

ឈ្មោះ ខេត្ត នៅ កម្ពុជាក្រោម។ ឈ្មោះដើម និង ឈ្មោះ យួន ដូរ បន្តបន្ទាប់មក ហើយ បំបែក ខេត្ត ខ្លះ ទៅ ជា ជ្រើន ខេត្ត :

មាត់ជ្រូក	Chaudoc - An Giang - long Xuyen
ទឹកខ្មៅ	Camau - Quan Long An xuyen
ឃ្លាំង (ជាសាក់)	Soctran - Khanh Hung - Ba Xuyen
ក្រមួនស ក្រមួនស-ពាមកោះត្រល់ - ព្រៃកឫស្សី	Rach Gia. Choung Thuyen. Can Tho. Ba Xuyen. Hau Giang Kieng Giang (Rach Gia, Ha tien) Phu Quoc
ពលលារ	Bac lieu - An Xuyen
ពាមជារាជ ពាមជារាជ-មាត់ជ្រូក	Long Xuyen - An Giang - Kien Phong
ពាម	Ha Tien - Kien Giang - Rach Rgia - Kien Giang
ទួលតាម៉ុក ទួលតាមោក	Thu Dong Mot - Binh Doung - Binh Long - Song Be Binh Phuoc

[5] G. AUBERET, capitaine de Frégate. Histoire et description de la base de Cochinchine (Pays Gia Dinh). សៀវភៅ នេះ លោក បាន បកប្រែ ពី ឯកសារយួន សរសេរ ជា ភាសាចិន នៅក្នុង រាជ្យ របស់ ព្រះចៅ Minh-mang ដោយ ឧត្តមមន្ត្រី យួន ឈ្មោះ Trang-hoï-Duc ជា ឧបរាជ យួន ត្រួតត្រា កម្ពុជាក្រោម នៅ ឆ្នាំ ១៨១០។ នៅ សម័យ នោះ យួន គេ អោយ ឈ្មោះ កម្ពុជាក្រោម ថា ស្រុក យា ដិន (Gia Dinh)។

ចិន ជា មិត្ត របស់ នរណា ?

ព្រះសួគ៌ា ព្រះសួគ៌ា - អ្ករកាប Phuoc Tuyo - Thuan Hai Baria-Vung Tau (Côn Dao) Tan An - Long An

អ្ករកាប Vung Tao - Cong Dao

ចន្ទ្ររ្ត្ត្ត្ត្ត ចង្ហ្ការ្ត្ត្ត្ត Bien Hoa - Phuoc Thanh - Dong Nai

លង់ហោ Vinh Long

ហ្ការ្ត្ត្ត Tay Ninh

ព្ការ្ត្ត Saigon

ម្ត្ត-ការ្ត្ត Tiên Giang (My Tho, Go Cong)

ការ្ត្ត Bên Tre

ការ្ត្ត Long An (Tan An)

ផ្ការ្ត្ត Dông Thap (Sa Dec)

ព្ការ្ត្ត Travinh (Vinh Binh)

ការ្ត្ត Con Dao (Con Son)

ចប់